ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងព្រហ្មទណ្ឌលេខ: ៤២៧
ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ: ១១១/១១ ក្រ.៣ "ង"
ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២

# នាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាអសាធារណៈ នៅសាលសវនាការនៃសាលាដំបូងខេត្តព្រះសីហនុ នាថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ និងថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះសីហនុ

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៤២៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ ដែលមាន៖

១. ជនជាប់ចោទឈ្មោះ [redacted] វិន ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ នៅលីវ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត [redacted] ខេត្តព្រះសីហនុ និងមានទីលំនៅបច្ចុប្បន្ននៅមុខពេលឃាត់ខ្លួននៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] រិទ្ធ (រ) ម្តាយឈ្មោះ [redacted] សាក់ (រ) ទោសពីមុនគ្មាន។ (ឃាត់ខ្លួន កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំលេខ: ៦២៨ ដ.ប.ឃ.ខ/ឃ/២២ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ)

២. ជនជាប់ចោទឈ្មោះ [redacted] ឃើញមែន ហៅ ឃៀង ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ នៅលីវ មុខរបររៀនជំនាញ មានទីកន្លែងកំណើត [redacted] ខេត្តព្រះសីហនុ និងមានទីលំនៅបច្ចុប្បន្ននៅមុខពេលឃាត់ខ្លួននៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ភីន (រ) ម្តាយឈ្មោះ [redacted] សារ៉េត (រ) ទោសពីមុនគ្មាន។ (ឃាត់ខ្លួន កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំលេខ: ៦២៩ ដ.ប.ឃ.ខ/ឃ/២២ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ)

៣. ជនជាប់ចោទឈ្មោះ [redacted] ចំណាន ភេទប្រុស កើតឆ្នាំ២០០៧ ជនជាតិខ្មែរ នៅលីវ មុខរបរបុគ្គលិកក្រុមហ៊ុនដឹកឥវ៉ាន់ មានទីកន្លែងកំណើតនៅ [redacted] ខេត្តព្រះសីហនុ និង

មានទីលំនៅបច្ចុប្បន្ននៅមុខពេលឃាត់ខ្លួននៅភូមិ២ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ចំណាប់ (រ) ម្ដាយឈ្មោះ [redacted] ស្រីណា (រ) ទោសពីមុនគ្មាន។ (ឃាត់ខ្លួន កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំលេខ: ៦៣០ ដ.ប.ឃ.ខ/យ/២២ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ)

ជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដែលមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឃើញមែន ហៅ ឃៀង ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ។

-ដែលមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចំណាន ភេទប្រុស កើតឆ្នាំ២០០៧ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] វិន ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ។

-ដែលមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិន ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] SIMAO ភេទប្រុស អាយុ៤០ ឆ្នាំ ជនជាតិចិន មានទីលំនៅបច្ចុប្បន្ននៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

-សាក្សីឈ្មោះ [redacted] សុខហ៊ី ជាមន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ។

-សាក្សីឈ្មោះ [redacted] ឃាន ជាមន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ។

-បានឃើញ របាយការណ៍សំយោគលេខ: ៣២៧ រ.ប.ក/២២ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៤០១ អ.យ.ង/២២ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាដំណោះស្រាយលេខ: ២១០ ដ.ដ.ស/យ/២២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២២ និង០០ នាទី នៅចំណុចផ្លូវរង្វង់មូលគោ២ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីអំពើលួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) មួយបានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទចំនួន៣ នាក់ មិនស្គាល់អត្តសញ្ញាណ បានធ្វើសកម្មភាពជិះម៉ូតូមួយគ្រឿងម៉ាក ហុងដាសេ១២៥ ឆ្នាំ២០២០ ពណ៌ខ្មៅ និងម៉ូតូមួយគ្រឿងម៉ាក NEX ពណ៌សពាក់ស្លាកលេខកំពត ១L-០១៨៧ បានឆក់កាបូបលុយពណ៌ខ្មៅមួយរបស់ជនជាតិចិនម្នាក់ ក្នុងខណៈពេលជនរងគ្រោះកំពុងដើរតាមផ្លូវ។ បន្ទាប់ពីបានទទួលបណ្តឹងរបស់ជនរងគ្រោះ កម្លាំងជំនាញនគរបាលព្រហ្មទណ្ឌកម្រិតស្រាល បានធ្វើការស្រាវជ្រាវរហូតដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង០០ និង៤០ នាទីរំលងអធ្រាត្រ ទើបឃាត់ខ្លួនជនជាប់ចោទចំនួន៣ នាក់ មានឈ្មោះ [redacted] ចំណាន, ឈ្មោះ [redacted] ឃើញមែន ហៅ ឃៀង និងជនជាប់ចោទឈ្មោះ [redacted] វិន។



Scanned with CamScanner

## នាពេលសួរនាករ

-ជនជាប់ចោទឈ្មោះ [redacted] ចំណាន បានឆ្លើយសារភាពថាៈ សមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំ នៅពេលកំពុងហូបប្រហិតជាមួយឈ្មោះ [redacted] ឃើញមែន និងឈ្មោះ [redacted] វិន។ ខ្ញុំមិនបានធ្វើសកម្មភាពឆក់កាបូបគេនោះទេ ដោយនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ខ្ញុំបានចេញពីធ្វើការ ហើយក៏បានទៅផ្ទះ ហើយនៅថ្ងៃទី១៨ និងថ្ងៃទី១៩ ខ្ញុំមិនបានដើរលេងនោះទេ។ នៅមុនពេលសមត្ថកិច្ច ខ្ញុំរើសបានទូរស័ព្ទមួយគ្រឿង Iphone ១៣ Pro នៅ កណ្ដាលផ្លូវក្បែរស្នងការនគរបាលខេត្តព្រះសីហនុ។ ទូរស័ព្ទដែលខ្ញុំរើសនោះរលត់ ដោយខ្ញុំរើសនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២។ ខ្ញុំធ្វើការបានប្រាក់ខែចំនួន២០០ ដុល្លារអាម៉េរិក ហើយម៉ូតូម៉ាក NEX ពណ៌ស ជាម៉ូតូរបស់ឈ្មោះ [redacted] វិន។ ខ្ញុំមិនទទួលយកចម្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌នោះទេ ពីព្រោះខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ហើយឈ្មោះ [redacted] វិន និងឈ្មោះ [redacted] ឃើញមែន ក៏មិនបានប្រព្រឹត្តដែរ។ ខ្ញុំមិនបានឆក់ទូរស័ព្ទដៃម៉ាក Iphone និងកាបូបដែលមានលុយ១,០០០ ដុល្លារអាម៉េរិកនោះទេ។ ខ្ញុំស្គាល់ឈ្មោះ [redacted] វិន និងឈ្មោះ ភិន ឃើញមែន។ ខ្ញុំបានបង្គោះម៉ូតូមានគ្នាប្រាំនាក់ នៅម៉ោង១១ យប់។

-ជនជាប់ចោទឈ្មោះ [redacted] ឃើញមែន ហៅ យៀង បានឆ្លើយសារភាពថាៈ ខ្ញុំមិនដែលស្គាល់ឈ្មោះ [redacted] ចំណាន នោះទេ ហើយចម្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ខ្ញុំមិនបានឆ្លើយទេ។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ខ្ញុំមិនបានចេញទៅណាទេ។ ឈ្មោះ [redacted] ចំណាន បានប្រាប់ខ្ញុំថាវារើសទូរស័ព្ទបាន ហើយម្ដងវាថាចៅកែវាទុកឱ្យប្រើ ដោយទូរស័ព្ទនោះអាចប្រើបាន។ ខ្ញុំបង្គោះម៉ូតូ ទើបសមត្ថកិច្ចចាប់មក។ ខ្ញុំមិនដែលស្គាល់ឈ្មោះ [redacted] វិន នោះទេ។ ខ្ញុំធ្វើការជាជាងកាត់សក់។ សមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំ និងបានវាយធ្វើបាបខ្ញុំ។ ខ្ញុំមិនចេះប្រើប្រាស់ថ្នាំញៀននោះទេ ហើយខ្ញុំក៏មិនធ្លាប់ធ្វើសកម្មភាពឆក់កាបូបជនជាតិចិននោះទេ ហើយពីមុនក៏មិនដែលធ្វើសកម្មភាពដែរ។

-ជនជាប់ចោទឈ្មោះ [redacted] វិន បានឆ្លើយសារភាពថាៈ ខ្ញុំស្គាល់ឈ្មោះ [redacted] ឃើញមែន និងឈ្មោះ [redacted] ចំណាន ដោយមិនដែលធ្វើសកម្មភាពឆក់នោះទេ។ សមត្ថកិច្ចបានចាប់ខ្លួន នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ ដោយសារខ្ញុំបង្គោះម៉ូតូ ដោយឈ្មោះ [redacted] ចំណាន ជាអ្នកបង្គោះ។ នៅពេលឃាត់ខ្លួន សមត្ថកិច្ចបានដកហូតទូរស័ព្ទដៃមួយគ្រឿង។ ខ្ញុំមិនមានភស្តុតាងណាបញ្ជាក់នោះទេ។ ឈ្មោះ [redacted] ចំណាន មិនដែលឱ្យលុយខ្ញុំទេ។ ខ្ញុំមិនបានឆ្លើយចម្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌នោះទេ ហើយខ្ញុំសូមបដិសេធចម្លើយនៅសមត្ថកិច្ចចោលទាំងស្រុង។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចំណាន នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថាៈ កន្លងមក ខ្ញុំធ្លាប់ចេញធ្វើសកម្មភាពឆក់បានមួយលើក គឺកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២១ និង៣០ នាទី ពួកខ្ញុំមានគ្នា៤ នាក់ ខ្ញុំ, ឈ្មោះ [redacted] ឃើញមែន, ឈ្មោះ [redacted] វិន និងឈ្មោះ [redacted] ខេមរ៉ា ដោយជិះម៉ូតូពីរគ្រឿងដោយខ្ញុំជិះម៉ូតូម៉ាក NEX ពណ៌ស ពាក់ស្លាកលេខកំពត ១L-០១៨៧ ជាមួយឈ្មោះ [redacted] ឃើញមែន។ រីឯ ឈ្មោះ [redacted] វិន ជិះម៉ូតូមួយគ្រឿងម៉ាកអាសង់ ពណ៌ខ្មៅ សេរីឆ្នាំ២០២២ ពាក់ស្លាកលេខ ១AO-៣៦០៦ ជាមួយឈ្មោះ [redacted] ខេមរ៉ា។ ពួកខ្ញុំទាំង៤ នាក់ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនជាតិខ្មែរ ភេទស្រី នៅខណៈពេលដែលជនរងគ្រោះកំពុងឈរនៅផ្លូវនិយាយទូរស័ព្ទនៅមាត់ផ្លូវរង្វង់មូលត្រីដូហ្វិន ដោយឈ្មោះ [redacted] វិន ជាអ្នកឆក់ ហើយឈ្មោះ [redacted] ខេមរ៉ា ជាអ្នកបើកម៉ូតូ ចំណែកខ្ញុំ និងឈ្មោះ [redacted] ឃើញមែន ជិះម៉ូតូបិទគូថ។ ទូរស័ព្ទដៃដែលពួកខ្ញុំឆក់ ម៉ាក Iphone ៧ ពណ៌ទឹកមាស ហើយក្រោយមកឈ្មោះ [redacted] វិន ជាអ្នកយកទៅលក់។ នៅវេលាម៉ោង០០ និង៤០ នាទី រំលងអធ្រាត្រ ឈានចូលថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ពួកខ្ញុំមានគ្នា០៥ នាក់ មានខ្ញុំ, ឈ្មោះ [redacted] សុភក្ត្រា, ឈ្មោះ [redacted] ខេមរ៉ា (ជិះម៉ូតូមួយគ្រឿងម៉ាកអា

សង់ សេរីឆ្នាំ២០២២ ពណ៌ខ្មៅ ពាក់ស្លាកលេខកណ្តាល ១AO-៣៦០៦) ឈ្មោះ[redacted]ឃើញមែន, ឈ្មោះ [redacted] វិន ជិះម៉ូតូមួយគ្រឿងម៉ាក NEX ពណ៌ស ពាក់ស្លាកលេខកំពត ១L-០១៨៧។ ពួកខ្ញុំបាននាំគ្នាជិះម៉ូតូដើររហូតដល់ផ្លូវស្ពានអូរគ្រែះ២ ពេលនោះស្រាប់តែឈ្មោះ [redacted] សុភត្រ្តា បានបបួលខ្ញុំបង្ហោះម៉ូតូលេង។ បន្ទាប់មក ឈ្មោះ[redacted] ខេមរ៉ា ក៏លើកម៉ូតូបង្ហោះលេង ដោយមានឈ្មោះ [redacted] សុភត្រា អង្គុយនៅកណ្តាល ហើយខ្ញុំអង្គុយនៅខាងក្រោយ។ រីឯ ម៉ូតូម៉ាក NEX មិនបានបង្ហោះទេ ដោយបានជិះទៅមុនពួកខ្ញុំ ក្នុងខណៈនោះស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនពួកខ្ញុំទាំងប្រាំនាក់ ដើម្បីត្រួតពិនិត្យក៏បានឃើញទូរស័ព្ទដៃមួយគ្រឿងម៉ាក Iphone ១៣ Pro ពណ៌ផ្ទៃមេឃដែលជាទូរស័ព្ទរបស់ជនជាតិចិននៅក្នុងហោប៉ៅរបស់ខ្ញុំ ហើយក៏បានឃាត់ខ្លួនពួកខ្ញុំទាំងប្រាំនាក់តែម្តង។ ចំពោះទូរស័ព្ទដៃមួយគ្រឿងម៉ាក Iphone ១៣ Pro ពណ៌ផ្ទៃមេឃ ដែលជាទូរស័ព្ទដៃរបស់ជនជាតិចិន គឺខ្ញុំបានរើសនៅពេលដែលខ្ញុំដឹកឥវ៉ាន់ កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងដប់ពីរថ្ងៃត្រង់ នៅចំណោតតាក្ខាន់ ដោយមិនបានឆក់ ឬលួចគេទេ។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឃើញមែន ហៅ ឃៀង នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា: កន្លងមក ខ្ញុំធ្លាប់បានធ្វើសកម្មភាពឆក់បានមួយលើក កាលពីថ្ងៃ១៩ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២១ និង៣០ នាទី ដោយមានគ្នាបួននាក់ មានខ្ញុំ, ឈ្មោះ [redacted] ចំណាន, ឈ្មោះ [redacted] វិន និងឈ្មោះ[redacted] ខេមរ៉ា បានជិះម៉ូតូពីរគ្រឿង ដោយខ្ញុំជិះម៉ូតូម៉ាកអាសង់ ពណ៌ខ្មៅ សេរីឆ្នាំ២០២២ ពាក់ស្លាកលេខកណ្តាល ១AO-៣៦០៦ ជាមួយឈ្មោះ [redacted] ចំណាន ហើយឈ្មោះ[redacted] វិន ជិះម៉ូតូម៉ាក NEX ពណ៌ស ពាក់ស្លាកលេខ កំពត ១L-០១៨៧ ជាមួយឈ្មោះ [redacted] ខេមរ៉ា ដោយពួកខ្ញុំទាំង៤ នាក់ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនជាតិខ្មែរ ភេទស្រី នៅខណៈពេលដែលជនរងគ្រោះកំពុងឈរផ្លូវនិយាយទូរស័ព្ទនៅមាត់ផ្លូវរង្វង់មូលត្រីដូហ្វីន ដោយឈ្មោះ [redacted] វិន ជាអ្នកឆក់ ហើយឈ្មោះ [redacted] ខេមរា ជាអ្នកបើកម៉ូតូ រីឯខ្ញុំ និងឈ្មោះ [redacted] ចំណាន ជិះម៉ូតូបិទគូថ។ ទូរស័ព្ទដៃដែលពួកខ្ញុំឆក់បានមានទូរស័ព្ទម៉ាក Iphone ៧ ពណ៌ទឹកមាស។ ហើយក្រោយមក ឈ្មោះ[redacted] វិន ជាអ្នកយក។ នៅវេលាម៉ោង០០ និង៤០ នាទី រំលងអធ្រាត្រ ឈានចូលថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ពួកខ្ញុំមានគ្នា៥ នាក់ មានខ្ញុំ, ឈ្មោះ [redacted] វិន ជិះម៉ូតូមួយគ្រឿងម៉ាក NEX ពណ៌ស ពាក់ស្លាកលេខ កំពត ១L-០១៨៧ និងឈ្មោះ [redacted] ចំណាន, ឈ្មោះ [redacted] ខេមរ៉ា និងឈ្មោះ [redacted] ភត្ត្រា ជិះម៉ូតូមួយគ្រឿងម៉ាកអាសង់ សេរីឆ្នាំ២០២២ ពណ៌ខ្មៅ ពាក់ស្លាកលេខកណ្តាល ១AO-៣៦០៦។ ពួកខ្ញុំបាននាំគ្នាជិះម៉ូតូទៅលេងនៅលើស្ពានអូរគ្រែះ២ ដើមឈើចាំស្នេហ៍ និងជិះដើរលេងទៅរូបសំណាកព្រះថោងនាងនាគ ពេលនោះស្រាប់តែគ្នារបស់ខ្ញុំទាំង៣ នាក់ ដែលជិះម៉ូតូម៉ាក អាសង់ សេរីឆ្នាំ២០២២ ពណ៌ខ្មៅ ពាក់ស្លាកលេខកណ្តាល ១AO-៣៦០៦ បានបង្ហោះម៉ូតូលេង ក្នុងខណៈនោះស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនពួកខ្ញុំទាំង៥ នាក់ ដើម្បីត្រួតពិនិត្យ ក៏បានឃើញទូរស័ព្ទដៃមួយគ្រឿងម៉ាក Iphone ១៣ Pro ពណ៌ផ្ទៃមេឃ ដែលជាទូរស័ព្ទរបស់ជនជាតិចិននៅក្នុងហោប៉ៅរបស់ឈ្មោះ [redacted] ចំណាន ហើយក៏បានឃាត់ខ្លួនពួកខ្ញុំតែម្តង។ ចំពោះទូរស័ព្ទមួយគ្រឿងម៉ាក Iphone ១៣ Pro ពណ៌ផ្ទៃមេឃ គឺជារបស់ឈ្មោះ [redacted] ចំណាន ដោយវាបានប្រាប់ខ្ញុំថា ចៅកែវាឱ្យប្រើទុកទាក់ទងដឹកឥវ៉ាន់ឱ្យភ្ញៀវ លុះដល់ពេលសមត្ថកិច្ចសួរនាំទើបវាប្រាប់ថា រើសបាន។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិន នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា: កន្លងមក ខ្ញុំធ្លាប់ចេញធ្វើសកម្មភាពឆក់ចំនួនពីរលើក ជាមួយបក្ខពួករបស់ខ្ញុំបីនាក់ មានឈ្មោះ [redacted] ចំណាន, ឈ្មោះ [redacted] ឃើញមែន និងឈ្មោះ[redacted] ខេមរ៉ា ដោយលើកទីមួយ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២២ ខ្ញុំទាំងបីនាក់ មានខ្ញុំ ឈ្មោះ[redacted] ចំណាន និងឈ្មោះ[redacted] ឃើញមែន ជិះម៉ូតូពីរគ្រឿង

ដោយខ្ញុំជិះម៉ូតូម៉ាក NEX ពណ៌ស ពាក់ស្លាកលេខ កំពត ១L-០១៨៧ ជាមួយឈ្មោះ [redacted] ចំណាន ហើយឈ្មោះ [redacted] ឃើញមែន ជិះម៉ូតូមួយគ្រឿងម៉ាកអាសង់ សេរីឆ្នាំ២០២០ មិនចាំផ្លាកលេខ តែម្នាក់ឯង ដោយវាខ្ចីម៉ូតូគេជិះ។ ពួកខ្ញុំទាំងបីនាក់ បានធ្វើសកម្មភាពឆក់កាបូបជនជាតិចិន ភេទប្រុស នៅជិតរង្វង់មូលគោ២ ដោយខ្ញុំជាអ្នកបើកម៉ូតូ ហើយឈ្មោះ [redacted] ចំណាន ជាអ្នកឆក់ រីឯឈ្មោះ [redacted] ឃើញមែន ហៅ ឃៀង ជាអ្នកជិះបិទគូថ ពេលឆក់បានហើយ ពួកខ្ញុំបានជិះម៉ូតូគេចទៅកន្ទុយនាគ រួចទើបឆែកកាបូបមើលដោយឃើញមានលុយចំនួន ១,០០០ ដុល្លារអាមេរិក ហើយពួកខ្ញុំក៏យកលុយនោះចែកគ្នា ដោយឈ្មោះ [redacted] ចំណាន ជាអ្នកចែកលុយ ហើយវាចែកលុយឱ្យខ្ញុំចំនួន២០០ ដុល្លារអាមេរិក ហើយឈ្មោះ [redacted] ឃើញមែន ចំនួន១៣០ ដុល្លារអាមេរិក និងបានយកទៅចែកជាមួយឈ្មោះ [redacted] ខេមរ៉ា ដែលជាម្ចាស់ម៉ូតូអាសង់ ពណ៌ខ្មៅ សេរីឆ្នាំ២០២២ ពាក់ស្លាកលេខកណ្ដាល ១AO-៣៦០៦ ចំនួន១០០ ដុល្លារអាមេរិក លុយសល់ប៉ុន្មានឈ្មោះ [redacted] ចំណាន យកទាំងអស់ និងលើកទីពីរ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២១ និង៣០ នាទី ពួកខ្ញុំមានគ្នា៤ នាក់ មានខ្ញុំ ឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន ឈ្មោះ [redacted] ខេមរ៉ា ជិះម៉ូតូពីរគ្រឿង ដោយខ្ញុំជិះម៉ូតូម៉ាក NEX ពណ៌ស ពាក់ស្លាកលេខ កំពត ១L-០១៨៧ ជាមួយឈ្មោះ [redacted] ឃើញមែន និងឈ្មោះ [redacted] ខេមរ៉ា ជិះម៉ូតូរបស់គាត់ម៉ាក អាសង់ ពណ៌ខ្មៅ សេរីឆ្នាំ២០២២ ពាក់ស្លាកលេខកណ្ដាល ១AO-៣៦០៦ ជាមួយឈ្មោះ [redacted] ចំណាន ហើយពួកខ្ញុំទាំង៤ នាក់ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនជាតិខ្មែរ ភេទស្រី ក្នុងខណៈពេលដែលជនរងគ្រោះកំពុងឈរផ្លូវនិយាយទូរស័ព្ទនៅមាត់ផ្លូវរង្វង់មូលត្រីម្ជូហ្វិន ដោយឈ្មោះ [redacted] ចំណាន ជាអ្នកឆក់ ហើយឈ្មោះ [redacted] ខេមរ៉ា ជាអ្នកបើកម៉ូតូ។ រីឯខ្ញុំ ជិះម៉ូតូដឹកឈ្មោះ [redacted] ឃើញមែន បិទគូថ។ ទូរស័ព្ទដៃដែលពួកខ្ញុំឆក់បានម៉ាក Iphone ៧ ពណ៌ទឹកមាស។ បន្ទាប់មក ឈ្មោះ [redacted] ខេមរ៉ា និងឈ្មោះ [redacted] ចំណាន បានយកទូរស័ព្ទទៅឈ្ងួសលេខកូដនៅហាងលក់ទូរស័ព្ទមួយកន្លែងក្បែរវត្តអូរគ្រេះ អស់ចំនួន១០ ដុល្លារអាមេរិក។ លុះព្រឹកឡើង ទើបពួកខ្ញុំទាំង៤ នាក់ បានយកទូរស័ព្ទនោះទៅលក់នៅកន្លែងដែលឈ្ងួសលេខកូដ បានតម្លៃ២០០ ដុល្លារអាមេរិក ហើយឈ្មោះ [redacted] ចំណាន បានចែកលុយឱ្យពួកខ្ញុំទាំងបីនាក់ ម្នាក់២០ ដុល្លារអាមេរិក សល់ប៉ុន្មានគាត់យកទាំងអស់។ នៅវេលាម៉ោង០០ និង៤០ នាទី រំលងអធ្រាត្រ ឈានចូលថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ពួកខ្ញុំមានគ្នា៥ នាក់ មានខ្ញុំ ឈ្មោះ [redacted] ឃើញមែន ជិះម៉ូតូមួយគ្រឿងម៉ាក NEX ពណ៌ស ពាក់ស្លាកលេខ កំពត ១L-០១៨៧ ឈ្មោះ [redacted] សុភក្ត្រា ឈ្មោះ [redacted] ខេមរ៉ា ឈ្មោះ [redacted] ចំណាន ជិះម៉ូតូមួយគ្រឿងម៉ាក អាសង់ ពណ៌ខ្មៅ សេរីឆ្នាំ២០២២ ពាក់ស្លាកលេខកណ្ដាល ១AO-៣៦០៦។ ពួកខ្ញុំបាននាំគ្នាជិះម៉ូតូដើរលេងរហូតដល់ផ្លូវស្ពានអូរគ្រេះ២។ បន្ទាប់មក គ្នារបស់ខ្ញុំទាំង៣ នាក់ ដែលជិះម៉ូតូអាសង់ ពណ៌ខ្មៅ សេរីឆ្នាំ២០២២ ពាក់ស្លាកលេខកណ្ដាល ១AO-៣៦០៦ បានបង្អោះម៉ូតូលេង ហើយសមត្ថកិច្ចបានមកដល់ឃាត់ខ្លួនពួកខ្ញុំទាំង៥ នាក់ ដើម្បីត្រួតពិនិត្យដោយបានឃើញទូរស័ព្ទដៃមួយគ្រឿងម៉ាក Iphone ១៣ Pro ពណ៌ផ្ទៃមេឃដែលជាទូរស័ព្ទដៃរបស់ជនជាតិចិននៅក្នុងហោប៉ៅរបស់ខ្ញុំ ហើយសមត្ថកិច្ចក៏ឃាត់ខ្លួនពួកខ្ញុំទាំង៥ នាក់ មកស្នងការនគរបាលខេត្តព្រះសីហនុតែម្ដង។ ចំពោះទូរស័ព្ទដៃមួយគ្រឿងម៉ាក Iphone ១៣ Pro ពណ៌ផ្ទៃមេឃ គឺជាទូរស័ព្ទរបស់ឈ្មោះ [redacted] ចំណាន ដោយគាត់អួតប្រាប់ពួកខ្ញុំថា ថៅកែគាត់ទុកឱ្យប្រើ លុះពេលដែលសមត្ថកិច្ចសួរនាំ ស្រាប់តែគាត់ប្រាប់ថារើសបានទៅវិញ។ ខ្ញុំសូមបញ្ជាក់ថា ឈ្មោះ [redacted] ចំណាន ធ្លាប់បាននិយាយប្រាប់ខ្ញុំថា គាត់ជាមួយបក្ខពួកគាត់ផ្សេងទៀត ធ្លាប់ធ្វើសកម្មភាពឆក់ជាច្រើនលើក។

-ក្រឡាបញ្ជីអានកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] SIMAO ឆ្លើយដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា: នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ខ្ញុំបានជិះយន្តហោះពី HENAN ប្រទេសចិន

មកខេត្តព្រះសីហនុ។ បន្ទាប់មក ខ្ញុំបានរកស៊ីប្តូរប្រាក់នៅតាមកាស៊ីណូ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២២ និង០០ នាទី ខ្ញុំបានដើរតាមផ្លូវទៅរង្វង់មូលតោ២ ដោយក្នុងដៃមានកាន់កាបូបកៀបក្លៀកមួយ ពណ៌ខ្មៅ ស្រាប់តែមានជនសង្ស័យពីរនាក់ បានជិះម៉ូតូមួយគ្រឿងម៉ាក NEX មិនចាំម៉ាក ជិះតាមពីក្រោយ ហើយខ្ញុំចំណាំបានអ្នកដែលឆក់កាបូបពីដៃរបស់ខ្ញុំ មានមាឌធំ សម្បុរខ្មៅ សក់រួញ។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងកាបូបរបស់ខ្ញុំមានលុយចំនួន១,០០០ ដុល្លារអាមេរិក។

-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ជនជាប់ចោទឈ្មោះ [redacted] វីន ជនជាប់ចោទឈ្មោះ [redacted] ចំណាន និងជនជាប់ចោទឈ្មោះ [redacted] ឃើញមែន ត្រូវបានដាក់ឱ្យស្ថិតក្រោមពិនិត្យពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការ តំណាងអយ្យការសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឃើញមែន បានសន្និដ្ឋានការពារថា: ឆ្លងតាមការពិភាក្សាសួរដេញដោលជនជាប់ចោទទាំងបីនាក់នាពេលសវនាការ តាមការចោទប្រកាន់របស់តំណាងអយ្យការពីបទ លួចមានស្ថានទម្ងន់ទោសនេះ ខ្ញុំសូមធ្វើការបដិសេធចោលទាំងស្រុង។ ពាក់ព័ន្ធនឹងការឃាត់ខ្លួនកូនក្តីខ្ញុំនេះ ហើយនឹងការចោទប្រកាន់របស់តំណាងអយ្យការមិនស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុពិតប្រាកដនោះទេ។ ការឃាត់ខ្លួនកូនក្តីខ្ញុំនេះ សមត្ថកិច្ចឃាត់ខ្លួនពាក់ព័ន្ធនឹងការបង្ហោះម៉ូតូនៅជិតដើមឈើចាំស្នេហ៍ ដោយកូនក្តីខ្ញុំ និងជនជាប់ចោទផ្សេងទៀត កំពុងអង្គុយហូបប្រហិត និងបង្ហោះម៉ូតូក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ដោយបានកសាងសំណុំរឿង និងបញ្ជូនជនជាប់ចោទមកកាន់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ហើយបានចោទប្រកាន់កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ពីបទ: អំពើលួចមានស្ថានទម្ងន់ទោស ដែលមានជនរងគ្រោះឈ្មោះ [redacted] SIMAO ដែលបានបាត់កាបូប និងប្រាក់ចំនួន១,០០០ ដុល្លារអាមេរិក ដោយចោទប្រកាន់កូនក្តីខ្ញុំជាអ្នកប្រព្រឹត្ត។ ប៉ុន្តែ បើពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងនេះ ក៏ដូចជាការដកហូតវត្ថុតាងលើជនជាប់ចោទនីមួយៗ គឺឃើញថា ការដកហូតលើកូនក្តីខ្ញុំ មានតែទូរស័ព្ទមួយគ្រឿងម៉ាក Iphone ១១។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ចំណាន គឺដកហូតបានទូរស័ព្ទម៉ាក Iphone ១៣ Pro ដែលគាត់បានអះអាងថាបានរើសបាននៅជិតកាស៊ីណូនៅជិតស្នងការនគរបាលខេត្តព្រះសីហនុ។ មួយវិញទៀត ការឃាត់ខ្លួននេះ ក៏មិនមែនជាការឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែងពាក់ព័ន្ធនឹងបទល្មើសអំពើលួច ឬមានការដេញប្រដាប់ប្រតឹងនោះដែរ ហើយឃើញថា ពាក់ព័ន្ធវត្ថុតាងនៅក្នុងសំណុំរឿងនេះទៀត ហើយនឹងការបាត់របស់ជនរងគ្រោះ គឺបាត់កាបូបលុយនិងលុយចំនួន១,០០០ ដុល្លារអាមេរិក ប៉ុន្តែនៅពេលនេះ ជនជាប់ចោទទាំងបីនាក់ បានឆ្លើយបដិសេធថា ពួកខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ហើយនៅថ្ងៃទី១៨ និងថ្ងៃទី១៩ គឺពួកគាត់មិនបានធ្វើសកម្មភាពនោះទេ គឺពួកគេនៅផ្ទះ ហើយពួកគាត់សុទ្ធតែមានមុខរបរត្រឹមត្រូវ ដែលរកប្រាក់ចំណូលបាន។ ដូច្នេះ ពួកគាត់មិនអាចប្រព្រឹត្តអំពើខុសច្បាប់ណាមួយដែលនាំឱ្យសង្គមស្អប់ខ្ពើមនោះទេ។ បើផ្អែកតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] SIMAO បានបញ្ជាក់ថា នៅវេលាម៉ោង២២ ជនរងគ្រោះជិះនៅរង្វង់មូលតោ ហើយជនជាប់ចោទជិះម៉ូតូម៉ាក NEX មិនចាំស្លាកលេខ តើនៅក្នុងស្ថានភាពនោះ គាត់ជាជនជាតិចិនតើគាត់ចាំម៉ូតូដែរឬទេ? ហើយនៅកន្លែងនោះមានភ្លើងបំភ្លឺគ្រប់គ្រាន់ដែរឬទេ? ហើយជនរងគ្រោះថា ម៉ូតូដែលធ្វើសកម្មភាពនោះម៉ាក NFX ហើយនៅពេលឃាត់ខ្លួនកូនក្តីខ្ញុំនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ឃើញមានជិះម៉ូតូម៉ាក NEX ទើបធ្វើការ



Scanned with CamScanner

កសាងសំណុំរឿងមកដាក់ច្បាស់ៗតែម្ដង ហើយជនបរទេសដែលមករស់នៅស្រុកខ្មែរ ខ្ញុំជឿជាក់ថា ពួកគាត់មិនស្គាល់ពីប្រភេទម៉ូតូច្បាស់នោះទេ ហើយវត្ថុតាងដែលខ្ញុំលើកឡើងនេះ មិនមានស៊ីសង្វាក់ទៅនឹងអង្គហេតុពិតប្រាកដនោះដែរ។ ដូច្នេះ គឺពុំមានភស្តុតាង ឬទឡ្ហីករណ៍ច្បាស់លាស់ដែលអាចចោទប្រកាន់កូនក្ដីខ្ញុំពីបទ អំពើលួចមានស្ថានទម្ងន់ទោសនោះដែរ ហើយពេលនេះសមត្ថកិច្ចមិនបានចូលមកឆ្លើយបំភ្លឺនាពេលសវនាការនោះទេ។ ដូច្នេះ ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឃើញមែន ស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឱ្យកូនក្ដីខ្ញុំរួចផុតពីបទចោទ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចំណាន បានសន្និដ្ឋានការពារថា: កូនក្ដីខ្ញុំបានឆ្លើយបដិសេធនាពេលសវនាការ កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ ដោយកូនក្ដីខ្ញុំបានបដិសេធចម្លើយដែលបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដោយសមត្ថកិច្ចបានកសាងសំណុំរឿងមកថាជនជាប់ចោទដែលជាកូនក្ដីរបស់ខ្ញុំ បានសារភាពថាកូនក្ដីខ្ញុំពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោសមែន ដោយបានធ្វើការឆក់កាបូបរបស់ជនរងគ្រោះ។ ប៉ុន្តែ ខ្ញុំសូមគាំទ្រការសន្និដ្ឋានរបស់សហភាតារបស់ខ្ញុំ ហើយខ្ញុំស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះ ស្នើសុំឱ្យកូនក្ដីរបស់ខ្ញុំរួចផុតពីបទចោទ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិន បានសន្និដ្ឋានការពារថា: ដោយសារតែខ្ញុំមិនបានចូលរួមសវនាការ ប៉ុន្តែខ្ញុំសូមយកការសន្និដ្ឋានរបស់សហភាតារបស់ខ្ញុំ មកធ្វើការសន្និដ្ឋានដូចតទៅ: កូនក្ដីខ្ញុំបានឆ្លើយបដិសេធចម្លើយនៅក្នុងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ចោលដោយសារថាមានការបង្ខិតបង្ខំ ហើយជនបរទេសមិនស្គាល់ម៉ូតូនេះទេ ហើយបើតាមខ្ញុំសិក្សាលើសំណុំរឿងជាក់ស្ដែងឃើញថា នៅក្នុងរបាយការណ៍លេខ០១/២៥ ទាក់ទងនឹងការសួរចម្លើយជនជាប់ចោទ គឺមិនមានអាណាព្យាបាល ឬមេធាវីចូលរួមទេ ប៉ុន្តែបើយើងយោងទៅលើច្បាប់ស្ដីពីយុត្តិធម៌អនីតិជន មាត្រា២២ បានចែងថា "រាល់ការសួរចម្លើយរបស់អនីតិជន ត្រូវមានមេធាវី ឬអ្នកតំណាងស្របច្បាប់ចូលរួម" បើនៅក្នុងការសួរដេញដោលនោះពុំមានការចូលរួមរបស់អាណាព្យាបាលទេ។ ដូច្នេះ ខ្ញុំស្នើសុំតុលាការធ្វើមោឃភាពទៅលើរបាយការណ៍របស់សមត្ថកិច្ចនោះ។ បើផ្អែកតាមមាត្រ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា "តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ"។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។ ដូច្នេះ ការចោទប្រកាន់លើកូនក្ដីខ្ញុំនេះ យោងទៅលើរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌នេះ ប៉ុន្តែ បើពិនិត្យមើលច្បាប់ស្ដីពីយុត្តិធម៌អនីតិជនវិញ គឺគាត់ធ្វើខុសនីតិវិធី ដូច្នេះខ្ញុំស្នើសុំមោឃភាពរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មិនមែនមោឃភាពនីតិវិធីទេ។ នៅក្នុងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានការបង្ខិតបង្ខំ និងមានការគំរាមកំហែង។ កូនក្ដីខ្ញុំមិនបានប្រព្រឹត្តដូចការចោទរបស់តំណាងអយ្យការនោះទេ សំណូមពរ ខ្ញុំស្នើសុំតុលាការផ្ដល់យុត្តិធម៌ដល់កូនក្ដីរបស់ខ្ញុំ និងស្នើសុំសម្រេចឱ្យកូនក្ដីខ្ញុំរួចផុតពីបទចោទ។

-តំណាងអយ្យការ បានសន្និដ្ឋានតបថា: ដោយសារតែសំណុំរឿងនេះ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះ។ ដូច្នេះ រាល់ការស្នើសុំមោឃភាពនីតិវិធីមិនអាចទទួលយកបានទេ។ មានន័យថា ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុន ប្រសិនបើមាន។ ហេតុនេះ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។

-សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វិន ជនជាប់ចោទឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ [redacted] ចំណាន ស្នើសុំតុលាការជួយរកយុត្តិធម៌ឱ្យខ្ញុំផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ និងភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២២ និង០០ នាទី មានបទល្មើសព្រហ្មទណ្ឌមួយបានកើតឡើង នៅចំណុចផ្លូវរង្វង់មូលគោ២ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន ហៅ ឃៀង និងជនជាប់ចោទឈ្មោះ [redacted] វិន ដែលបានធ្វើសកម្មភាពឆក់កាបូបខ្មៅមួយរបស់ជនរងគ្រោះជនជាតិចិនឈ្មោះ [redacted] SIMAO ដោយជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន ហៅ ឃៀង និងជនជាប់ចោទឈ្មោះ [redacted] វិន បានជិះម៉ូតូពីរគ្រឿងម៉ាក ហុងដាសេ ១២៥ ឆ្នាំ២០២០ ពណ៌ខ្មៅ និងម៉ូតូមួយគ្រឿងម៉ាក NEX ពណ៌ស ផ្លាកលេខកំពត១L-០១៨៧ នៅពេលដែលជនរងគ្រោះកំពុងដើរតាមផ្លូវ។ បន្ទាប់មក ជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹងនៅការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល ហើយកម្លាំងជំនាញ ក៏បានធ្វើការស្រាវជ្រាវរហូតដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង០០ និង៤០ នាទី រំលងអធ្រាត្រ ក៏បានធ្វើការឃាត់ខ្លួនជនជាប់ចោទទាំងបីនាក់នេះតែម្តង។ ករណីនេះ ត្រូវបានច្បាប់កំណត់ ពីបទ: អំពើលួចមានស្ថានទម្ងន់ទោស ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. ជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ [redacted] វិន នាពេលសវនាការ បានឆ្លើយបដិសេធថា ខ្លួនមិនបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះដែលជាជនជាតិចិននោះទេ។ មិនតែប៉ុណ្ណោះ នៅដំណាក់កាលចៅក្រមស៊ើបសួរជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ [redacted] វិន ក៏បានឆ្លើយបដិសេធចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ផងដែរ ដោយអះអាងថា សមត្ថកិច្ចមិនបានអានឱ្យស្តាប់ ហើយបានវាយធ្វើបាបខ្លួន។ ចម្លើយនេះមិនអាចឱ្យតុលាការជឿបានទេ វាគ្រាន់តែជាលេសដោះសារ ដើម្បីឱ្យរួចផុតពីការចោទប្រកាន់របស់តំណាងអយ្យការ។ លើសពីនេះទៀត ជនជាប់ចោទទាំងបីនាក់នេះ មិនបានដាក់សាក្សី ឬភស្តុតាងដោះបន្ទុកណាមួយមកតុលាការ ដើម្បីឱ្យតុលាការពិនិត្យ និងសម្រេចនោះទេ។ ប៉ុន្តែ បើផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច និងអំណានចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលនគរបាលយុត្តិធម៌ និងអំណានចម្លើយរបស់ជនរងគ្រោះ ព្រមទាំងភស្តុតាងផ្សេងៗ មានភាពស៊ីសង្វាក់គ្នាដែលបង្ហាញឱ្យឃើញថា ជនជាប់ចោទទាំងបីនាក់នេះ ពិតជាបានធ្វើសកម្មភាពដូចការចោទប្រកាន់របស់តំណាងអយ្យការ ប្រាកដមែន។ ស្របពេលនឹងគ្នានេះដែរ សកម្មភាពរបស់ជនជាប់ចោទនេះ មិនបានប្រព្រឹត្តអំពើហិង្សា ឬការកាប់គាស់ទម្លុះទម្លាយដែលនាំឱ្យមានស្ថានទម្ងន់ទោសនោះទេ។ ដូច្នេះ ផ្អែកតាមដីកាសន្និដ្ឋានស្ថាពរលេខ: ៤០១ អ.យ.ង/២២ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងអយ្យការ និងដីកាដំណោះស្រាយលេខ: ២១០ ដ.ដ.ស/ឃ/២២ ចុះថ្ងៃទី២០



Scanned with CamScanner

ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ បានធ្វើការចោទប្រកាន់លើជនជាប់ចោទ ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ពុំត្រឹមត្រូវតាមអង្គហេតុឡើយ។ ដូច្នេះ តុលាការគប្បីកែតម្រូវឱ្យត្រូវទៅតាមអង្គហេតុ និងអង្គច្បាប់។ ហេតុនេះ គប្បីកែប្រែបទចោទ ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ មកបទៈ អំពើលួច ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ទើបត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ដែលកើតឡើងជាក់ស្ដែង។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ [redacted] វិន គឺជាអង្គហេតុត្រូវនឹងបទល្មើស អំពើលួច ដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣. ជនជាប់ចោទឈ្មោះ [redacted] ចំណាន និងជនជាប់ចោទឈ្មោះ [redacted] វិន ជាអនីតិជន ប៉ុន្តែមានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។ ហេតុនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការផ្ដន្ទាទោសលើជនជាប់ចោទ ដោយផ្អែកតាមបញ្ញត្តិមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៤. ជនជាប់ចោទឈ្មោះ [redacted] ឃើញមែន ជានីតិជន មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៥. សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ [redacted] វិន ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោស ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែល នោះពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់នោះទេ គប្បីកែតម្រូវឱ្យបានត្រឹមត្រូវ។

៦. សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ពុំមានលក្ខណៈត្រឹមត្រូវនោះទេ ដោយសារតែមេធាវី ពុំបានបង្ហាញភស្តុតាង និងពុំបានដាក់ភស្តុតាងផ្ទុយណាមួយមកតុលាការ ដើម្បីមានទឡ្ហីករណ៍គ្រប់គ្រាន់សម្រាប់ឱ្យតុលាការជឿជាក់បានទេ។ ជាងនេះទៅទៀត មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានស្នើសុំមោឃភាពរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដោយអះអាងថាចម្លើយដែលជនជាប់ចោទបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ជាចម្លើយបានមកដោយការបង្ខិតបង្ខំ និងការវាយធ្វើបាបរបស់មន្ត្រីនគរបាលយុត្តិធម៌។ ការសន្និដ្ឋាននេះ ក៏ពុំមានមូលដ្ឋានគ្រប់គ្រាន់ទេ ពីព្រោះទាំងមេធាវី និងជនជាប់ចោទ ក៏ពុំបានបង្ហាញភស្តុតាងមកតុលាការ ដើម្បីឱ្យតុលាការពិនិត្យ និងពិចារណាដែរ។ លើសពីនេះទៀត ដោយសារតែសំណុំរឿងនេះ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះ។ ដូច្នេះ រាល់ការស្នើសុំមោឃភាពនីតិវិធីមិនអាចទទួលយកបានទេ។ មានន័យថា ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុន ប្រសិនបើមាន។ ហេតុនេះ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។

៧. ពុំមានភស្តុតាងដាក់បន្ទុក និងពុំមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ [redacted] វិន ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៨. មានភស្តុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ [redacted] វិន ពីបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៩. អំពើដែលជនជាប់ចោទឈ្មោះ [redacted] ចំណាន ឈ្មោះ [redacted] ឃើញមែន និងជនជាប់ចោទឈ្មោះ ឆន វិន បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ព្រមទាំងប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទ តុលាការនឹងពិនិត្យពិចារណា។

១០. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] SIAO មិនបានចូលមកតុលាការ ដើម្បីប្តឹងទាមទារសំណងជំងឺចិត្តពីជនជាប់ចោទនោះទេ។ ដូច្នេះ តុលាការទុកសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្តពីជនជាប់ចោទនាពេលក្រោយ។

## ហេតុដូច្នេះសម្រេច

១. កែប្រែបទចោទលើឈ្មោះ [redacted] ចំណាន ភេទប្រុស កើតឆ្នាំ២០០៧ ជនជាតិខ្មែរ និងឈ្មោះ [redacted] វិន ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឃើញមែន ហៅ **ឃៀង** ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ ពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ មកបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២. ផ្តន្ទាទោសឈ្មោះ [redacted] ចំណាន ភេទប្រុស កើតឆ្នាំ២០០៧ ជនជាតិខ្មែរ និងឈ្មោះ [redacted] វិន ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេលចំនួន ០៨ (ប្រាំបី) ខែ ពីបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៣. ផ្តន្ទាទោសឈ្មោះ [redacted] ឃើញមែន ហៅ **ឃៀង** ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន០១ (មួយ) ឆ្នាំ ពីបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៤. សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ និងថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងចំពោះមុខមេធាវីរបស់ជនជាប់ចោទ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាអហោធារណៈ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ រក្សាសិទ្ធិប្តឹងមាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

.................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ០៩កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]